ក្រុមជំនុំមេតូឌីស្ទនៅកម្ពុជា
THE METHODIST CHURCH IN CAMBODIA

# មេរៀនទី ១១៖ ម៉ូសេ និងអេលីយ៉ាបានបង្ហាញខ្លួនជាមួយព្រះយេស៊ូវ

## លូកា ៩៖២៨-៣៦

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/DeYj1p7wGtw

**គោលបំណង៖** យើងត្រូវស្តាប់ព្រះយេស៊ូវ

**ខគម្ពីរចងចាំ៖ លូកា ៩:៣៥** *"ហើយមានសំឡេងចេញពីពពកមកថា នេះជាកូនស្ងួនភ្ងាអញ ចូរឲ្យស្តាប់តាមចុះ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. កូនតូចៗអើយ https://youtu.be/ewu6Tfpo5Vo

២. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

៣. ខ្ញុំចូលតាមទ្វារព្រះអង្គ https://youtu.be/WvXL4DtBMdc

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ស្តាប់ព្រះសូរសៀង»

១. ចែកកុមារទាំងអស់ជា២ក្រុមធំៗ (កនិងខ)

២. ដោយក្រុម(ក)ចែកជា២ទៀតគឺ (ក១) និង(ក២) ចំណែកក្រុម(ខ)នៅមួយក្រុមដដែល

៣ .ក្រុម(ខ)ឈរនៅកណ្តាលរវាងក្រុម(ក១) និង (ក២)

៤.ក្រុម(ក១)ត្រូវបញ្ជូនសារទៅកាន់ក្រុម(ក២)ដោយនិយាយតែមួយប្រយោគទេ (ឧ.ព្រះយេស៊ូវស្រលាញ់ ឬ ព្រះយេស៊ូវប្រទានពរ។ល។) តែមិនឲ្យក្រុម ក២ ដឹងពីសារនោះមុនទេ

៥. ក្រុម(ខ)មានតួនាទីស្រែករំខានក្រុម(ក១)និង(ក២) នៅពេលគេព្យាយាមបញ្ជូនសារនោះទៅ ឲ្យគ្នា។

៦. គ្រូកុមារសួរទៅកាន់ក្រុម (ក២) ថាតើប្អូនស្តាប់ឮប្រយោគអ្វី? បន្ទាប់មកសួរទៅកាន់ក្រុម (ក១) ថាតើប្រយោគនោះត្រឹមត្រូវដែរឬទេ?

៧. បន្ទាប់មកក្រុម(ខ)លេងល្បែងនេះម្តង ដោយធ្វើដូចជាក្រុម ក ធ្វើដែរ គឺចែកក្រុមជា ២ ថែមទៀត ហើយបញ្ជូនសារឲ្យគ្នា។

## ៤. ការណែនាំមេរៀន "ការផ្លាស់ប្រែ"



ក.សរសេរពាក្យថា **"ការផ្លាស់ប្រែ"** នៅលើក្តារខៀន (ឬបោះ-ពុម្ពរូបភាពនៅទំព័រខាងក្រោម) ដើម្បីបង្ហាញដល់កុមារ

ខ. សួរកុមារថាពួកគេគិតថាតើពាក្យនេះមានអត្ថន័យយ៉ាងម៉េច?

គ. បង្ហាញរូបភាពនៃមេអំបៅ និងពន្យល់ពីរបៀបដែលវាផ្លាស់ប្តូរ និងប្រែរូបរាង ពីដង្កូវទៅជាមេអំបៅដ៏ស្រស់ស្អាត។ "ការផ្លាស់ប្រែ" អាចមានលក្ខណៈបែបយ៉ាងដូច្នេះអីចឹង! ថ្ងៃនេះយើងនឹងរៀនជាមួយគ្នាអំពីការផ្លាស់ប្រែរបស់ព្រះយេស៊ូវ។

## ៥. រឿងនៅ ក្នុងព្រះគម្ពីរ

រឿងក្នុងព្រះគម្ពីរថ្ងៃនេះប្រាប់យើងអំពីគ្រាមួយដែលព្រះយេស៊ូវបាននាំពេត្រុស យ៉ូហាន និងយ៉ាកុប ទៅលើភ្នំមួយដើម្បីអធិស្ឋាន ។ ប៉ុន្តែសិស្សទាំងបីនាក់ងងុយដេកយ៉ាងខ្លាំង។ នៅពេលដែលព្រះយេស៊ូវកំពុងអធិស្ឋាន ព្រះភក្ត្រនិងព្រះពស្ត្ររបស់ទ្រង់ប្រែជាភ្លឺចែងចាំង ដូចជាពន្លឺផ្លេកបន្ទោរ! ព្រះយេស៊ូវបានស្លៀកពាក់ ពេញដោយសិរីល្អរបស់ព្រះ ដោយសារទ្រង់គឺជាស្តេច។ នៅក្នុងព្រះគម្ពីរយើងហៅ ការនេះថាជា«ការផ្លាស់ប្រែ»។ លោកពេត្រុស យ៉ូហាន និង យ៉ាកុប ក៏បានឃើញពីសិរីល្អរបស់ព្រះ!

ប៉ុន្តែសាច់រឿងមិនបានចប់ត្រឹមនេះទេ! ម៉ូសេ និងអេលីយ៉ាដែលមាននៅក្នុងគម្ពីរសញ្ញាចាស់បានលេចមកហើយចាប់ផ្តើមទូលនឹង(និយាយជាមួយ)ព្រះយេស៊ូវ។ ព្រះគម្ពីរចែងថា សូម្បីតែពួកគេទាំងពីរក៏ភ្លឺចែង-ចាំងដែរ។ ការនេះបានបង្ហាញយើងពីសម្លៀកបំពាក់បែបណាដែលយើងនឹងស្លៀកពាក់នៅពេលយើងទៅស្ថានសួគ៌។ សម្លៀកបំពាក់របស់ យើងនឹងភ្លឺចែងចាំង!

ពួកសិស្សអាចស្តាប់ឮលោកម៉ូសេ និងអេលីយ៉ាទូលនឹងព្រះយេស៊ូវអំពីការចាកចេញពីផែនដីរបស់ទ្រង់។ ព្រះយេស៊ូវទ្រង់ជ្រាបពីពេលវេលាដែលទ្រង់ត្រូវសុគតលើឈើឆ្កាងកាន់តែកៀកមកហើយ។

ពេលនោះមានពពកបានគ្របបាំងពួកគេទាំងអស់គ្នានៅលើភ្នំ ហើយមានសំឡេងចេញពីពពកមកថា **លូកា ៩:៣៥** “នេះជាកូនស្ងួនភ្ងាអញ ចូរឲ្យស្តាប់តាមចុះ” ។ នោះជាសំឡេងរបស់ព្រះជាម្ចាស់! ព្រះអង្គ បានមានបន្ទូលប្រាប់ពួកសិស្សថា ពួកគេត្រូវតែស្តាប់តាមព្រះយេស៊ូវ ។ ចុះកូនវិញ? តើកូនគិតថាកូនគួរ ស្តាប់តាមព្រះយេស៊ូវដែរឬទេ? ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះដែលបានយាងមកសុគតជំនួសយើង ដើម្បីឲ្យយើងអាចត្រឡប់ទៅផ្ទះរបស់យើងនៅឯនគរស្ថានសួគ៌វិញ។ មានតែសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវប៉ុណ្ណោះ ដែលអាចនាំយើងទៅរកព្រះជាម្ចាស់បាន។ សូមឲ្យយើងស្តាប់តាមព្រះយេស៊ូវ ហើយដើរតាមទ្រង់គ្រប់ៗគ្នា!

## ៦. សំនួរពិភាក្សា

១. តើសាវកណាខ្លះបានធ្វើដំណើរទៅលើភ្នំជាមួយនឹងព្រះយេស៊ូវ? (*ពេត្រុស យ៉ូហាន និងយ៉ាកុប*)
២. ហេតុអ្វីបានជាព្រះយេស៊ូវឡើងទៅលើភ្នំ? (*ដើម្បីអធិស្ឋាន*)
៣. តើមានអ្វីកើតឡើងចំពោះព្រះយេស៊ូវក្នុងពេលដែលទ្រង់កំពុងអធិស្ឋាន? (*ព្រះភក្ត្រ និងព្រះពស្ត្រទ្រង់មានភាពផ្លាស់ប្រែទៅជាភ្លឺចែងចាំង*)
៤. តើអ្នកណាខ្លះនៅក្នុងគម្ពីរសញ្ញាចាស់មកនិយាយជាមួយព្រះយេស៊ូវ? (*ម៉ូសេ និងអេលីយ៉ា*)
៥. ហេតុអ្វីបានជាយើងត្រូវតែស្តាប់ព្រះយេស៊ូវ?
(*ព្រះជាម្ចាស់បានបង្គាប់យើងឲ្យស្តាប់តាមព្រះយេស៊ូវ*)

## ៧. ល្បែងកំសាន្ត «ផ្លាស់ប្តូរទៅជាសត្វពាហនៈ»

ក. បែងចែកកុមារជាក្រុមដែលមានគ្នាពី៤ទៅ៥នាក់ក្នុង១ក្រុម

ខ. ក្នុងក្រុមនីមួយៗ ចាត់កុមារម្នាក់មកឈរខាងមុខគេ (អាចចាត់ទុកថាជាមេក្រុម)
គ. តំណាងក្រុមនីមួយៗ ត្រូវធ្វើខ្លួនរបស់ពួកគេឲ្យក្លាយទៅជាអ្វីដែលគ្រូប្រាប់ឲ្យធ្វើ។ ឧទាហរណ៍៖ បើសិនគ្រូនិយាយថា “សត្វដំរី” ដូច្នេះកុមារនឹងព្យាយាមធ្វើខ្លួនឲ្យដូចជាសត្វដំរី។ គ្រូ និងកុមារផ្សេងទៀតនឹងសំរេចចិត្តថាតើកុមារតំណាងក្រុមមួយណាធ្វើដូចសត្វដំរីជាងគេ។
ឃ. កុមារថ្មីម្នាក់ទៀតពីក្នុងក្រុមដដែលនឹងឡើងមកឈរនៅខាងមុខដើម្បីបន្តលេងល្បែងនេះ។
ង. ទាំងនេះជាគំនិតមួយចំនួន: សត្វតោ កណ្តុរ ទន្សាយ ពស់ បក្សី ឆ្កែ ឆ្មា

**៨. ខគម្ពីរចងចាំ**

**លូកា ៩៖៣៥** *“ហើយមានសំឡេងចេញពីពពកមកថា នេះជាកូនស្ងួនភ្ងាអញ ចូរឲ្យស្តាប់តាមចុះ”។*

**៩. ហាត្ថកម្ម** **«ផាត់ពណ៌រូបភាព ការផ្លាស់ប្រែ »**

ឲ្យកុមារគ្រប់គ្នាសរសេរខគម្ពីរចងចាំ ពេលដែលពួកគេផាត់ពណ៌រូបភាពចប់។

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
នៅក្នុងសាច់រឿងនៃព្រះគម្ពីរថ្ងៃនេះ សាវកដែលងោកងុយស្ទើរតែខកខាននូវការមើលឃើញពី “សិរីល្អរបស់ព្រះយេស៊ូវ” ទៅហើយ ពីព្រោះពួកគេអស់កម្លាំងជាខ្លាំង (ដូចជានៅក្នុងសួនច្បារកេតសេម៉ានី)។ នៅក្នុងជីវិតរបស់អ្នក តើមានអ្វីខ្លះដែលកំពុងតែលួចយកថាមពលរបស់អ្នក និងកំពុងតែរំខានអ្នកពីការធ្វើនូវរឿងសំខាន់ផ្សេងៗនៅក្នុងជីវិត? តើអ្វីខ្លះដែលអ្នកអាចលុបចេញពី កាលវិភាគប្រចាំថ្ងៃរបស់អ្នក? ជ្រើសរើសពេល វេលាដ៏ល្អបំផុតណាមួយដើម្បី ចំណាយពេលជាមួយ ព្រះដូច្នេះអ្នកនឹងអាចទទួលបាន បទពិសោធន៍ ពីការអស្ចារ្យរបស់ព្រះ។



# Transfiguration



**Memory Verse**: